# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ ០៣២៥/០៧ ស.ខ.ក.ក.

## ក្រាបបង្គំទូលថ្វាយ

## ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី ឯកភាពជាតិខ្មែរ ជាទីគោរពដ៏ខ្ពង់ខ្ពស់

ទូលព្រះបង្គំជាខ្ញុំថាច់ សេដ្ឋា អតីតសមាជិកព្រឹទ្ធសភា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាតំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ ទ្រង់ព្រះមេត្តាជ្រាបថា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៧ មានសង្ឃរាជគណៈដឹកនាំដោយព្រះតេជគុណណយ ច្រឹក, ព្រះតេជគុណឡឹម ហេង និងព្រះតេជគុណឡុង គីមលាង ចុះទៅចាប់ផ្សឹកព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដិន ខាងជើង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្ត តាកែវ ដែលមានដើមកំណើតនៅកម្ពុជាក្រោម តាមលិខិតរបស់សម្ដេចព្រះសង្ឃនាយកនួន ង៉ែតលេខ៥០២/០៧ ស.ន.ច.ជ. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៧ ដោយបានចោទប្រកាន់ថា ព្រះតេជគុណទឹម សាខន ថាបានប្រព្រឹត្តខុសនឹងវិន័យព្រះពុទ្ធសាសនា ដែលបានធ្វើឱ្យបែកបាក់សាមគ្គីជាតិ-អន្តរជាតិ ជាពិសេសរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម ដោយយកទីអារាមធ្វើជាទីបញ្ជាការសម្រាប់បំរើចលនាឃោសនាដែលធ្វើឱ្យប៉ះពាល់ដល់វិន័យ និងសេចក្ដីថ្លៃថ្នូរព្រះពុទ្ធសាសនា ។

*បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់!*

តាមព្រះវិន័យព្រះពុទ្ធសាសនា ការចាប់ផ្សឹកភិក្ខុសង្ឃអង្គណាមួយបាន លុះត្រាតែព្រះសង្ឃអង្គនោះ បានប្រព្រឹត្តល្មើសក្នុងសិក្ខាបទណាមួយនៃអាបត្តិបារាជិកទាំង៤ ។ ដូចនេះព្រះតេជគុណទឹម សាខន មិនបានប្រព្រឹត្តខុសនឹងព្រះវិន័យក្នុងព្រះពុទ្ធសាសនា ដូចការចោទប្រកាន់ទេ ។ តាមការចុះស្រាវជ្រាវដល់វត្តភ្នំដិនខាងជើងកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ របស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងកំណត់ហេតុសមត្ថកិច្ច ដែលចុះឆែកឆេរពុំបានរកឃើញវត្ថុតាងអ្វីគួរឱ្យកត់សម្គាល់ថា ព្រះតេជគុណទឹម សាខនអាចធ្វើសកម្មភាពបំបែកបំបាក់មិត្តភាពកម្ពុជា-វៀតណាមបានឡើយ ។ ជាពិសេសព្រះមេគណខេត្តតាកែវ បានមានសង្ឃដិកាប្រាប់អង្គ




ភូមិគ្រឹះលេខ៩៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៩៨១, ១២ ៨៥១ ៩៥១ / ៩០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo

ការ-សមាគមខ្មែរកម្ពុជាក្រោម ដែលបានចូលទៅថ្វាយបង្គំព្រះអង្គកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ថាព្រះអង្គពុំបានដឹងថា ព្រះតេជគុណទឹម សាខន បានធ្វើអ្វីខុសទេ ការដែលនាំព្រះតេជគុណទឹម សាខនមកចាប់ផ្សឹកក្នុងវត្តរបស់ព្រះអង្គគ្រាន់តែគេ(សង្ឃរាជគណៈ)ខ្ចីវត្តព្រះអង្គតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត តាមសេចក្ដីរាយការណ៍របស់កាសែត The Cambodia Daily ចេញផ្សាយថ្ងៃនេះ(០២-០៧-០៧) ដោយស្រង់បន្ទូលសម្ដេចព្រះអគ្គមហាសង្ឃាធិបតីទេព វង្សថា *នៅ១១អង្គទៀត ត្រូវចាប់ផ្សឹកហើយបញ្ជូនឱ្យអាជ្ញាធរយួន*។ តាមសេចក្ដីរាយការណ៍របស់កាសែត The Cambodia Daily ថ្ងៃនេះ(០៣-០៧-០៧)ថា ព្រះតេជគុណទឹម សាខន ត្រូវបានអាជ្ញាធរខ្មែរបញ្ជូនទៅឱ្យអាជ្ញាធរវៀតណាមហើយតាមសំណូមពររបស់ព្រះអង្គ ។ ករណីនេះ ទូលព្រះបង្គំយើងខ្ញុំយល់ ឃើញថា មិនពិតទេ ពិព្រោះ:

ទី១-ក្រោយពីការចាប់ផ្សឹកភ្លាម មានជនមិនស្គាល់អត្តសញ្ញាណមួយក្រុមបាននាំខ្លួនព្រះអង្គតាមរថយន្តបញ្ជូនទៅឱ្យអាជ្ញាធរវៀតណាមយ៉ាងតក់ក្រហាលបំផុត តើព្រះអង្គមានពេលឯណាធ្វើលិខិតសំណូមពរមកក្រសួងមហាផ្ទៃសុំឱ្យបញ្ជូនព្រះអង្គទៅប្រទេសវៀតណាម ។

ទី២-ម្ដាយឪពុក បងប្អូនរបស់ព្រះតេជគុណ នៅក្បែរវត្តភ្នំដិនទាំងអស់តើព្រះអង្គចង់ទៅប្រទេសវៀតណាមជួបអ្នកណា?

ទី៣-ការចាប់ផ្សឹកបានចោទប្រកាន់ថាព្រះអង្គបានប្រឆាំងអាជ្ញាធរវៀតណាម តើហេតុអ្វីបានជាព្រះអង្គចង់ទៅប្រទេសវៀតណាមឱ្យអាជ្ញាធរវៀត ណាមសម្លាប់ទៅវិញ ។ ដូច្នេះហេតុផលទាំងនេះពុំត្រឹមត្រូវឡើយ ។

សេចក្ដីដូចបានក្រាបបង្គំទូលថ្វាយខាងលើ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាត ទូលសូមព្រះរាជអន្តរាគមន៍ដ៏ខ្ពង់ខ្ពស់ ពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ទៅរាជរដ្ឋាភិបាលខ្មែរដើម្បី:

១- សូមបញ្ជូនព្រះតេជគុណទឹម សាខនត្រឡប់មកកម្ពុជាវិញ

២- បញ្ឈប់ជាបន្ទាន់រាល់ការចាប់ផ្សឹកព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោមជាបន្តទៀត លើកលែងតែត្រូវអាបត្តិបរាជិក ។

៣- បញ្ឈប់រាល់ការគំរាមកំហែងមកលើព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោម និងថ្នាក់ដឹកនាំអង្គការសមាគមខ្មែរកម្ពុជាក្រោម

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះរាជអគ្គមហេសី ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ បានជាសះស្បើយពីព្រះរោ

គាផងទាំងពួង មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់កូន ចៅ ចៅទួត របស់ព្រះអង្គនៅគ្រប់ទិសទីតរៀងទៅ ។

សូមព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះមេត្តាទទួលនូវគារវកិច្ចដ៏ស្មោះបំផុត អំពីទូលព្រះបង្គំយើងខ្ញុំ ។

សេចក្ដីពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះរាជទានប្រោស ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ កក្កដា ឆ្នាំ២០០៧*

តំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម